# សេចក្តីជូនដំណឹង
# ស្តីពីការ ជ្រើសរើសក្រុមហ៊ុន ចូលរួមការដេញថ្លៃ
# សម្រាប់កិច្ចសន្យាសាងសង់ ជីកស្រះទឹក ចំនួន១កន្លែង

## *១. សេចក្តីផ្តើម*

អង្គការអភិវឌ្ឍន៍សំលេងសហគមន៍(BCV) ជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ធ្វើការមិនស្វែងរកប្រាក់ចំណេញ មិនមាននិន្នាការបម្រើបក្សនយោបាយ និងមិនប្រកាន់សាសនា។ ដើម្បីចូលរួមចំណែកជាមួយរដ្ឋាភិបាលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រ ធ្វើការកសាង និងអភិវឌ្ឍន៍ធនធានមនុស្សដោយធ្វើការផ្តោតលើគោលនយោបាយលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងកាត់បន្ថយភាពក្រីក្រនៅថ្នាក់មូលដ្ឋាន។ អង្គការអភិវឌ្ឍន៍សំលេងសហគមន៍(BCV) ដោយបានការគាំទ្រថវិកាពី UNDP GEF SGP ប្រចាំប្រទេសកម្ពុជានៃគម្រោង ***បង្កើនជីវភាពរបស់សហគមន៍ តាមរយៈអេកូទេសចរណ៍ និងការអភិរក្សធនធានធម្មជាតិ*** ដែលអនុវត្តគម្រោងនៅសហគមន៍តំបន់ការពារធម្មជាតិព្រៃធំអន្លង់ថ្ម មានតាំងនៅភូមិងយនិងភូមិជីពូក ឃុំក្បាលទឹក ស្រុកទឹកផុល ខេត្តកំពង់ឆ្នាំង ដែលមានលេខកូដគម្រោង KHM/CBA3/2023/02 ។

**សមាសធាតុសម្រាប់ការងារដេញថ្លៃ៖**

***ការអញ្ជើញចូលរួមស្នើសុំការដេញថ្លៃជាសាធារណៈលើការផ្គត់ផ្គង់ ជីកស្រះទឹកចំនួន១កន្លែង ។***

ប្រភេទលទ្ធកម្ម៖ ការដាក់ពាក្យស្នើសុំដេញថ្លៃសម្រាប់ ជីកស្រះទឹក ។

**ទីតាំង៖** ភូមិងយ ឃុំក្បាលទឹក ស្រុកទឹកផុល ខេត្តកំពង់ឆ្នាំង។

## *២. លក្ខខណ្ឌក្នុងការដេញថ្លៃ*

- តម្លៃប៉ាន់ស្មានសរុប៖ តម្លៃជីកស្រះទឹក ១,៩៤៩.២៤ ដុល្លាអាមេរិក (គិតរួមទាំងVAT១០% ឬពន្ធកាត់ទុក១៥%)
- ក្រុមហ៊ុន អ្នកម៉ៅការសំណង់ ម្ចាស់សហគ្រាស សិប្បកម្ម និងអ្នកទទួលផ្គត់ផ្គង់ធ្វើសំណង់ ត្រូវបំពេញឯកសារឲ្យបានពេញលេញ (សូមបញ្ជាក់ឲ្យបានច្បាស់នូវតម្លៃ) ត្រូវច្រកក្នុងស្រោមសំបុត្របិទឱ្យជិតដោយមានចុះហត្ថលេខាត្រារបស់ក្រុមហ៊ុននៅលើស្រោមសំបុត្រ រួចផ្ញើមកកាន់ ការិយាល័យអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ ដែលមានអាសយដ្ឋាន ផ្ទះលេខ១៧អា ផ្លូវ៤៦៨ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមក រាជធានីភ្នំពេញ ឬ ផ្ញើរតាមរយៈអ៊ីម៉ែល chanthy@bcv-cambodia.org ព័ត៌មានបន្ថែមអាចទាក់ទងមកកាន់លេខទូរសព្ទ ០៨៩ ៨៨ ៥៦ ២៥ ។

- ក្រុមហ៊ុន អ្នកម៉ៅការសំណង់ ម្ចាស់សហគ្រាស សិប្បកម្ម និងអ្នកទទួលផ្គត់ផ្គង់ធ្វើសំណង់ ទាំងអស់ដែលមានប្រភពតែមួយអាចដាក់សំណើរដេញថ្លៃបានតែមួយគត់ ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុន អ្នកម៉ៅការសំណង់ ម្ចាស់សហគ្រាស សិប្បកម្ម និងអ្នកទទួលផ្គត់ផ្គង់ធ្វើសំណង់ ដែលបានចូលរួមធ្វើការដេញថ្លៃជាក្រុមហ៊ុនមានសម្ព័ន្ធភាពជាមួយ ឬ ប្រភពតែមួយ នឹងត្រូវបដិសេធដោយស្វ័យប្រវត្តិ ។
- រាល់ឯកសារដេញថ្លៃ អ្នកចូលរួមដេញថ្លៃទាំងអស់ (ដោយគិតជាប្រាក់ដុល្លារ ឬ ប្រាក់រៀល) ហើយត្រូវបញ្ចូលពន្ធអាករលើតម្លៃបន្ថែម ១០% ឬពន្ធកាត់ទុក១៥% ។
- រាល់ឯកសារដេញថ្លៃទាំងអស់ ដែលមិនបានដាក់ជូនមកការិយាល័យអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ ទាន់ពេលវេលាទេ ត្រូវចាត់ទុកជាអាសាបង់។
- ថ្នាក់គ្រប់គ្រង និងគណៈកម្មការលទ្ធកម្មនឹងបើកការប្រជុំនៅក្រោយថ្ងៃបិទបញ្ចប់ទទួលឯកសារដេញថ្លៃ និងធ្វើការសម្រេចយកអ្នកផ្គត់ផ្គង់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សមស្របទៅតាមលក្ខណៈវិនិច្ឆ័យរបស់ថ្នាក់គ្រប់គ្រង នឹងគណៈកម្មការលទ្ធកម្ម។ រាល់ឯកសារដែលបានដាក់មក ដើម្បីធ្វើការដេញថ្លៃទាំងឡាយនឹងត្រូវបានរក្សាទុកជាការសម្ងាត់ ។
- ថ្នាក់គ្រប់គ្រង នឹងគណៈកម្មការលទ្ធកម្ម សូមរក្សាសិទ្ធិរបស់ខ្លួនក្នុងការបដិសេធ ប្រសិនជាសំណុំឯកសារដេញថ្លៃណាមួយដែលមិនត្រឹមត្រូវ ។
- អ្នកដេញថ្លៃដែលទទួលបានជោគជ័យតែប៉ុណ្ណោះ នឹងត្រូវបានជូនដំណឹង។
- កាលបរិច្ឆេទចាប់ផ្តើមទទួលពាក្យ ចាប់ពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦។
- កាលបរិច្ឆេទឈប់ទទួលពាក្យ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៦ វេលាម៉ោង ១៧:៣០ នាទីល្ងាច។
- ទីកន្លែងនៃការប្រជុំបើកសំណើដេញថ្លៃ នៅទីស្នាក់ការអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ ផ្ទះលេខ១៧អា ផ្លូវ៤៦៨ សង្កាត់ទួលទំពូងទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។
- កាលបរិច្ឆេទនៃការប្រជុំបើកសំណើដេញថ្លៃ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៦។
- ពេលវេលាបើកសំណើដេញថ្លៃ នៅម៉ោង ១០:៣០នាទីព្រឹក តាមរយៈZoom Meeting ឬ ដោយផ្ទាល់ ។
- រយៈពេលសុពលភាពនៃសំណើដេញថ្លៃ ចំនួន ៣០ថ្ងៃ ចាប់ពីថ្ងៃប្រជុំបើកសំណើដេញថ្លៃ។
- យើងខ្ញុំសូមរក្សាសិទ្ធក្នុងការផ្លាស់ប្តូរនៃការបើកកញ្ចប់ឯកសារដេញថ្លៃ ប្រសិនបើមានការចាំបាច់ ហើយយើងខ្ញុំនិងជូនដំណឹងទៅ ក្រុមហ៊ុន អ្នកម៉ៅការសំណង់ ម្ចាស់សហគ្រាស សិប្បកម្ម និងអ្នកទទួលផ្គត់ផ្គង់ធ្វើសំណង់។
- រាល់ឯកសារដេញថ្លៃដែលបានដាក់មកហើយ យើងខ្ញុំមិនប្រគល់ជូនត្រឡប់វិញទេ។
- ក្រុមហ៊ុន អ្នកម៉ៅការសំណង់ ម្ចាស់សហគ្រាស សិប្បកម្ម និងអ្នកទទួលផ្គត់ផ្គង់ធ្វើសំណង់ ដែលឈ្នះក្នុងការដេញថ្លៃ ក្រុមការងារអង្គការអភិវឌ្ឍន៍សំលេងសហគមន៍ និងទាក់ទងទៅ ដើម្បីផ្តល់ព័ត៌មានលម្អិត។

## ៣. ឯកសារចាំបាច់នៃការដេញថ្លៃ

1. ប័ណ្ណប៉ាតង់ដែលមានសុពលភាព (ថតចម្លង ០១ច្បាប់)
2. វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ប្រសិនជាមាន (ថតចម្លង ០១ច្បាប់)
3. អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ លិខិតឆ្លងដែន (ថតចំលង ០១ច្បាប់) ។
4. ឯកសារពាក់ព័ន្ធផ្សេងៗប្រសិនបើមាន។

## ៤. តារាងជីកស្រះទឹក ចំនួន១កន្លែង

➢ *តារាងលម្អិតសម្រាប់ជីកស្រះទឹក នៅភូមិងយ ឃុំក្បាលទឹក ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង*

| ល.រ , | ប្រភេទសម្ភារៈ | ចំនួន | ចំនួនដេញថ្លៃ |
|---|---|---|---|
| ១ | ជីកស្រះទឹក | បណ្តោយ២៥ម៉ែត្រ X ទទឹង១៦ម៉ែត្រ ជម្រៅ ៤ម៉ែត្រ ។ | |
| ២ | ឈ្នួលពលកម្ម | ១ | |
| | | ***សរុប៖*** | |

ថ្ងៃពុធ ១១រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦

នាយិកាប្រតិបត្តិ

ព្រី ផល្លីភួង